01008791



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 08 / 2014
ម៉ោង (Time/Heure): 11:35
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤

## សវនាការបឋមបន្ថែម

រៀបចំដោយ៖ សែ កុលវុឌ្ឍី និង Robynne CROFT

| |
|---|
| **កំណត់ហេតុអ្នកចូលរួម** |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា Robynne CROFT |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជា លាង, លោក Nicholas KOUMJIAN, លោក William SMITH, លោក សេង ប៊ុនឃាង, លោក សេង លាង, កញ្ញា សុង ឆវ័ន្ត, លោក ស្រ៊ា រនត:, លោក Tarik ABDULHAK, លោក Salim NAKHJAVANI, លោក Mr. Andrew BOYLE |
| ជនជាប់ចោទ៖ លោក នួន ជា (ចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោម), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក សួន វិសាល, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក សំ សុគង់, លោក ឡៅ ជុនធី, លោក ហុង គីមសួន, លោក វ៉ែន ពៅ, លោក គីម ម៉េងឃី, លោកស្រី ជេត |

| |
|---|
| វណ្ណលី, លោកស្រី ទី ស្រ៊ីនណា, លោកស្រី ស៊ិន សុវន, លោក Yiqiang LIU, លោកស្រី Eleonor FERNANDEZ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី សួ សុធារី |
| ផ្សេងៗ៖ កញ្ញា Alix JANSSENS, លោក Russell HOPKINS, កញ្ញា ជា ស៊ីវហ័ង |

| ពេលវេលាទូទៅរបស់តុលាការ៖ | | |
|---|---|---|
| ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៥.១៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.១៥ | បញ្ចប់ម៉ោង៖ ១៣.៣៥ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង ៣៥ នាទី |

| កិច្ចដំណើរការនីតិវិធីផ្សេងទៀត | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| សេចក្តីសម្រេចលើការចូលរួមសវនាការរបស់ ជនជាប់ចោទ នួន ជា ពីបន្ទប់ឃុំខ្លួន ដោយសារបញ្ហាសុខភាព | មេធាវីការពារក្តី នួន ជា | ០៩.០៣ | ០៩.០៥ |
| សំណើសុំទទួលស្គាល់សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថ្មី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថ្មី | សហមេធាវីនាំមុខ | ០៩.១២ | ០៩.១៥ |
| ការបញ្ជាក់បន្ថែមលើសំណងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ | សហមេធាវីនាំមុខ | ០៩.១៧ | ០៩.៤៥ |
| បញ្ហាអញ្ញត្រកម្ម និងបញ្ហាច្បាប់នានាដែលនៅសល់ | អង្គជំនុំជម្រះ | ០៩.៤៥ | ០៩.៤៩ |
| សំណើសុំការបញ្ជាក់បន្ថែមអំពីសញ្ញាណនៃសំណុំរឿង ០០២/០១ ដែលចាត់ទុកជា | មេធាវីការពារក្តី ខៀវ សំផន | ០៩.៥០ | ១០.១១ |

| | | | |
|---|---|---|---|
| “មូលដ្ឋានទូទៅ” នៃសំណុំរឿង ០០២/០១ សម្រាប់ការជំនុំជម្រះក្រោយៗទៀត | | | |
| សំណើទាក់ទងនឹងការផ្លាស់ប្តូរការកំណត់បទចោទ និងទម្រង់នៃការទទួលខុសត្រូវដែលបានដាក់បញ្ចូលនៅក្នុងដីការដំណោះស្រាយពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ | សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខ<br>មេធាវីការពារក្តី ខៀវ សំផន | ១០.១២ | ១០.១៨ |
| លទ្ធភាពនៃការចូលរួមសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ | សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ១០.១៩ | ១០.២៩ |
| លំដាប់លំដោយនៃការជំនុំជម្រះ | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១០.៥១ | ១១.១៧ |
| ការពិនិត្យទៅលើបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី | សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ១១.២២ | ១៥.១៣ |
| សំណើសុំឱ្យមានសវនាការអសាធារណៈ | សហព្រះរាជអាជ្ញា | ១១.៤៤ | ១១.៥២ |
| សំណើសុំមិនប្រើរហស្សនាមសាក្សីមួយចំនួន | មេធាវីការពារក្តី នួន ជា | ១៤.១៣ | ១៤.២៥ |
| សំណើសុំពេលវេលាបន្ថែមក្នុងការដាក់ចម្លើយតបពាក់ព័ន្ធនឹងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង | មេធាវីការពារក្តី ខៀវ សំផន | ១៤.៥៥ | ១៥.០៦ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**សេចក្ដីសម្រេចលើការចូលរួមសវនាការរបស់ ជនជាប់ចោទ នួន ជា ពីបន្ទប់ឃុំខ្លួនដោយសារបញ្ហាសុខភាព**

អង្គជំនុំជម្រះបានសម្រេចថា ជនជាប់ចោទ នួន ជា អាចចូលរួមសវនាការបឋមបន្ថែមនេះពីបន្ទប់ឃុំខ្លួនដោយសារបញ្ហាសុខភាពរបស់គាត់។

**សំណើសុំទទួលស្គាល់ សហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីថ្មី និង មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីថ្មី**

អង្គជំនុំជម្រះបានទទួលស្គាល់លោកស្រី Marie GUIRAUD ជាសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងលោក Yiqiang LIU ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**ការបញ្ជាក់បន្ថែមលើសំណងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២**

មេធាវីនាំមុខ បានបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណង ដែលខ្លួនមានបំណងចង់ស្នើសុំនៅក្នុងបណ្ដឹងទាមទារសំណងចុងក្រោយ សម្រាប់សំណងផ្លូវចិត្ត និងសមូហភាពនៅក្នុងសំណុំរឿង ០០២/០២។ សហព្រះរាជអាជ្ញា គាំទ្រការបញ្ជាក់លើសំណងរដ្ឋប្បវេណីរបស់មេធាវីនាំមុខ។ មេធាវីការពារក្ដី ខៀវ សំផន បានកត់សម្គាល់ បន្តិចបន្តួចលើបញ្ហាសំណងនេះ។

**បញ្ហាអញ្ញត្រកម្ម និងបញ្ហាច្បាប់នានាដែលនៅសល់ក្នុងសំណុំរឿង ០០២/០២**

អង្គជំនុំជម្រះបានជូនដំណឹងទៅកាន់ភាគីថា នៅមានអញ្ញត្រកម្មចំនួនពីរ ដែលនៅសេសសល់នៅក្នុងសំណុំរឿង ០០២/០២ ដែលនឹងត្រូវយកមកដោះស្រាយនៅពេលនេះ ហើយអង្គជំនុំជម្រះនឹងចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរអំពីអញ្ញត្រកម្មទាំងពីរនេះ ឲ្យបានឆាប់តាមដែលអាចធ្វើបាននាពេលខាងមុខ។

**សំណើសុំការបញ្ជាក់បន្ថែមអំពីសញ្ញាណនៃសំណុំរឿង ០០២/០១ ដែលចាត់ទុកជា "មូលដ្ឋានទូទៅ" នៃសំណុំរឿង ០០២/០១ សម្រាប់ការជំនុំជម្រះ ក្រោយៗទៀត**

មេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំការបញ្ជាក់បន្ថែមអំពីសញ្ញាណនៃសំណុំរឿង ០០២/០១ ដែលចាត់ទុកជា "មូលដ្ឋានទូទៅ" សម្រាប់ការជំនុំជម្រះនាពេលក្រោយទៀតក្នុងសំណុំរឿង ០០២ ហើយនិងស្នើសុំផងដែរនូវការបញ្ជាក់បន្ថែមអំពីបញ្ហាមួយចំនួន ដែលបានកើតមានឡើងដោយសារ ការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម មានដូចជា តួនាទីរបស់ជនជាប់ចោទ និងផលប៉ះពាល់នៃសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើបណ្ដឹងឧទ្ធរណ៍ នៃសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមរបស់អង្គជំនុំជម្រះសាលាដំបូង។

ការិយាល័យសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដី នួន ជា បានធ្វើការកត់សម្គាល់ទៅលើសំណើរបស់

មេធាវីការពារក្ដី ខៀវ សំផន។ មេធាវីការពារក្ដី នួន ជា បានស្នើឱ្យមានសវនាការបឋមបន្ថែមមួយទៀត ដោយផ្ដោតទៅលើបញ្ហានេះ បន្ទាប់ពីការប្រកាសសាលក្រមនៃសំណុំរឿង ០០២/០១។ មេធាវីការពារក្ដី ខៀវ សំផន គាំទ្រសំណើសុំនេះ។

**<u>សំណើទាក់ទងនឹងការផ្លាស់ប្ដូរការកំណត់បទចោទ</u>**

ការិយាល័យសហព្រះរាជអាជ្ញា បានជូនដំណឹងអំពីបំណងរបស់ខ្លួនក្នុងការប្ដឹងសារទុក្ខទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលរកឃើញថា សហឧក្រិដ្ឋកម្មរួមមិនមែនជាផ្នែកមួយនៃច្បាប់អន្តរជាតិក្នុងអំឡុងពេលយុត្តាធិការរបស់ អ.វ.ត.ក។ សហព្រះរាជអាជ្ញាបានគាំទ្រសំណើរបស់មេធាវីការពារក្ដីដែលសុំឱ្យមានសវនាការបឋមបន្ថែមអំពីបញ្ហា "មូលដ្ឋានទូទៅ" បន្ទាប់ពីការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០១ ហើយបានស្នើសុំប្រើប្រាស់រហស្សនាមចាស់របស់សាក្សី ចំពោះសាក្សីណាដែលមានរហស្សនាមនៅក្នុងសំណុំរឿង ០០២/០១ រួចហើយ។

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីការពារក្ដី ខៀវ សំផន មិនបានដាក់សំណើជាក់លាក់ណាមួយឡើយ ប៉ុន្តែស្នើសុំការអនុញ្ញាតដើម្បីដាក់សំណើជាលាយលក្ខណ៍អក្សរ ប្រសិនបើខ្លួនយល់ថាចាំបាច់។

**<u>ព័ត៌មានអំពីលទ្ធភាពរបស់ភាគីក្នុងការចូលរួមការធ្វើសវនាការស្ដាប់ភ័ស្តុតាងនៃសំណុំរឿង ០០២/០២</u>**

ភាគីទាំងអស់បានជូនដំណឹងដល់អង្គជំនុំជម្រះអំពីលទ្ធភាពរបស់ខ្លួនក្នុងការចូលរួមសវនាការលើភ័ស្តុតាងនៅក្នុងឆ្នាំ ២០១៤ និងឆ្នាំ ២០១៥។ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានជូនដំណឹងថា ប្រសិនបើមានបណ្ដឹងសារទុក្ខក្នុងសំណុំរឿង ០០២/០១ ពួកគេមិនមានការជំទាស់អំពីការបន្ថយចំនួនថ្ងៃនៃសវនាការ រហូតដល់បញ្ចប់ការធ្វើសារណាបណ្ដឹងសាទុក្ខនោះទេ។ មេធាវីការពារក្ដី នួន ជា ជម្រុញឱ្យការធ្វើសវនាការចាប់ផ្ដើមពីម៉ោង ០៧.២០ ព្រឹក ដោយសារកូនក្ដីរបស់ខ្លួនអាចមានការផ្ដង់ស្មារតីបានល្អនៅពេលព្រឹក។ មេធាវីការពារក្ដី ខៀវ សំផន បានរក្សាគោលជំហររបស់ខ្លួនពាក់ព័ន្ធនឹងការកំណត់ថ្ងៃសវនាការ។

**<u>លំដាប់លំដោយនៃការជំនុំជម្រះ</u>**

មេធាវីការពារក្ដី នួន ជា និងមេធាវីការពារក្ដី ខៀវ សំផន បានធ្វើការសន្និដ្ឋានអំពីលំដាប់លំដោយនៃអង្គហេតុដែលបានស្នើសុំសម្រាប់ជំនុំជម្រះ ហើយសហព្រះរាជអាជ្ញា និងសហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការឆ្លើយតប។

**<u>ការពិនិត្យបញ្ជីឈ្មោះសាក្សី អ្នកជំនាញ ដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ភាគីបានពិភាក្សាដេញដោលអំពីបញ្ជីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានស្នើសុំ ។

**<u>សំណើសុំឱ្យមានសវនាការ អសាធារណៈ</u>**

អង្គជំនុំជម្រះ បានបដិសេធចោលសំណើពីសហព្រះអាជ្ញាដែលបានស្នើឱ្យមានសវនាការអសាធារណៈ

01008796



ដើម្បីពិភាក្សាអំពីសាក្សីមួយចំនួន។

**<u>សំណើសុំមិនប្រើរហស្សនាម សាក្សីមួយចំនួន</u>**

អង្គជំនុំជម្រះបានអនុញ្ញាតិឱ្យ មេធាវីការពារក្ដី នួន ជា ប្រើប្រាស់ឈ្មោះរបស់សាក្សីដែលបានស្នើ រួមមានសាក្សី 2-TCW-878, 2-TCW-831 និង 2-TCW-951។

**<u>សំណើសុំពេលវេលាបន្ថែមក្នុងការដាក់សារណាតបពាក់ព័ន្ធនឹង វិធាន៨៧(៤) នៃវិធានផ្ទៃក្នុង</u>**

មេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំពេលវេលាបន្ថែមចំនួន ១០ ថ្ងៃ ក្នុងការដាក់សារណាតបពាក់ព័ន្ធនឹងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះបានសម្រេចថា សំណើសុំពេលវេលាបន្ថែមនេះ មិនចាំបាច់ធ្វើជាលាយលក្ខណ៍អក្សរនោះទេ ហើយនឹងសម្រេចទៅលើសំណើនៅពេលក្រោយ។

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសាលាដំបូងបានសម្រេចឱ្យជនជាប់ចោទ នួន ជា ចូលរួមសវនាការពីបន្ទប់ឃុំខ្លួន។
- សម្រេចទទួលស្គាល់លោកស្រី Marie GUIRAUD ជាសហមេធាវីអន្តរជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងលោក Yiqiang LIU ជាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។
- អនុញ្ញាតិឱ្យប្រើប្រាស់ឈ្មោះសាក្សីមួយចំនួន ជំនួសឱ្យរហស្សនាម ក្នុងសវនាការ។
- សម្រេចឱ្យមេធាវីការពារក្ដី ខៀវ សំផន ធ្វើសំណើសុំបន្ថែមពេលវេលាសម្រាប់សារណាតបពាក់ព័ន្ធទៅនឹងវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ដោយផ្ទាល់មាត់។
- អង្គជំនុំជម្រះផ្អាកកិច្ចដំណើរការសវនាការ
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ។

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការត្រូវបានផ្អាក ហើយអង្គជំនុំជម្រះបានជម្រាបជូនដំណឹងថា សវនាការប្រកាសសាលក្រមនៃសំណុំរឿង ០០២/០១ នឹងធ្វើឡើងនៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០១៤។

ភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤

ជ. សែ [illegible] [illegible] CROFT